ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី រៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ២នាក់**

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានជួយសម្របសម្រួលមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ**២នាក់៖**

១- ពលការិនី **ក.ខ** អាយុ២៤ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង បានទៅធ្វើការតាមផ្ទះនៅម៉ាឡេស៊ីពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ តាមរយៈជនជាតិម៉ាឡេស៊ីម្នាក់។ ពលការិនី បានទទួលប្រាក់ខែគ្រប់ចំនួន ប៉ុន្តែដោយសារម្តាយរបស់នាងមានជំងឺជាទម្ងន់ នាងបានទៅស្ថានទូតនៅថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ២០១៦ ស្នើជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានចេញលិខិតធ្វើដំណើរ និងជូននាងទៅបង់ពិន័យនៅការិយាល័យអន្តោ-ប្រវេសន៍ម៉ាឡេស៊ី។

២- ពលការិនី **ស.ស.ក** អាយុ៣៦ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ចាម បានធ្វើដំណើរទៅម៉ាឡេស៊ីជាលើកទី២ដោយខ្លួនឯង ហើយបានធ្វើការតាមផ្ទះ ពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤។ ពលការិនី បានទទួលប្រាក់ខែគ្រប់ចំនួន ប៉ុន្តែដោយសារការងារលំបាក នាងបានទៅស្ថានទូតនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្នើជួយឲ្យបានត្រឡប់ទៅកម្ពុជា។ ស្ថានទូតបានចេញលិខិតធ្វើដំណើរ និងជូននាងទៅបង់ពិន័យនៅការិយាល័យអន្តោ-ប្រវេសន៍ម៉ាឡេស៊ី។

ពលការិនី**ក.ខ** និងពលការិនី**ស.ស.ក** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៣** ខែ**វិច្ឆិកា** ឆ្នាំ **២០១៦** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមជើងយន្តហោះលេខ AK 536 ។

អំឡុងពេលរង់ចាំមកកម្ពុជា ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនីទាំងពីរនាក់ផងដែរ។

ភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ